**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**

-លេខ: ៧៦ "ក្រ៣ជ"
ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ:២១៥៦
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ:១៣២៧
ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ:៤៣៩៨
ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩ វេលាម៉ោង១៤ និង ០០ នាទីរសៀលនៅសាលសវនាការទី៥ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២១៥៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ដែលមាន**ជនជាប់ចោទ**៖

១-ឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅជំរំ [redacted] មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] **ឃុន** (រ) ម្តាយឈ្មោះ [redacted] **សំអឿន** (ស) ប្រពន្ធឈ្មោះ [redacted] **ស្រីលាភ** មានកូន១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ ។

-ឃុំខ្លួនតាមដីលេខ៣២១២ (ឋ) ដ.ឃ.ដ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

២-ឈ្មោះ [redacted] **ចន្ទ័វត្ថា**ហៅ **ស្នូក** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កា [redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលចាប់ខ្លួនស្នាក់នៅមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] **វ៉េន**(ស)ម្តាយឈ្មោះ [redacted] **សាង** (រ) ជានីតិជន ធ្លាប់ជាប់មណ្ឌលឱកាសខ្ញុំរយៈពេល៧ខែ ។

-ឃាត់ខ្លួននៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ ។

-ឃុំខ្លួនតាមដីកាលេខ៣២១៣ (ឋ) ដ.ឃ.ដ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ត្រូវជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុម៣៨ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ តាមបញ្ញាតិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង១១,៥០នាទីកម្លាំងជំនាញប្រឆាំងគ្រឿងញៀនបានចុះបង្ក្រាបមុខសញ្ញាចែកចាយគ្រឿងញៀន ក្នុងមូលដ្ឋានខណ្ឌដូនពេញដឹកនាំដោយលោកអធិការរងបានធ្វើការបង្ក្រាបជាក់ស្តែងក្នុងករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវរថភ្លើង សង្កាត់ស្រះចកដោយបានធ្វើការឃាត់ខ្លួនជនត្រូវចោទចំនួន២នាក់គឺឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចន្ទ័វត្ថា ដែលកំពង់ធ្វើសកម្មភាពលក់គ្រឿងញៀន ពេលនេះសមត្ថកិច្ចក៏បានធ្វើការឆែកឆេរលើជនត្រូវចោទ [redacted] សីហា បានរកឃើញនូវក្រាមសថ្លាចំនួន៤កញ្ចប់ធំ និង២

កញ្ចប់តូច ប្រភេទមេតំហ្វេតាមីនមានទម្ងន់៤៣,៥១ក្រាម ចំណែកឈ្មោះ [redacted] ចន្ទ័វុត្ថា បានរកឃើញក្រាមពណ៌ស ចំនួន១កញ្ចប់ធំប្រភេទមេតំហ្វេតាមីនមានទម្ងន់៩,៧២ក្រាម កាន់នឹងដៃស្តាំរបស់ឈ្មោះ [redacted] ចន្ទ័វុត្ថា រួចហើយក៏បាន កសាងសំណុំរឿងបញ្ជូនជនត្រូវចោទមកកាន់តុលាការ ក្រោយការស៊ើបអង្កេតចប់សព្វគ្រប់ជនត្រូវចោទឈ្មោះ [redacted] សីហា បានទិញគ្រឿងញៀនពីបុរសម្នាក់អាយុប្រហែល១៥ឆ្នាំ ចំណែកឈ្មោះ [redacted] ចន្ទ័វុត្ថា បានទិញថ្នាំញៀនពីបុរស ម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣៦ឆ្នាំដើម្បីលក់បន្តបានប្រាក់ចំណេញ ។

-បានឃើញ: របាយការណ៍សំយោគលេខ០១៧/១៩ រ.ប.ក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ របស់អធិការនគរ បាល ខណ្ឌដូនពេញ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ: ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៣៤៤ អ.យ.ម ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ ៤០៨១ អ.យ.ម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់អយ្យការអម សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ: ដីកាដំណោះស្រាយលេខ ៥៤៧៧ (ឋ) ដ.ដ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រម ស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សីហា ឆ្លើយនៅពេលសវនាការថា៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ វេលា ម៉ោង១១,៣០នាទីនៅចំណុចផ្លូវរថភ្លើង ក្រុម៣៩ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ មុនពេលដែលសមត្ថកិច្ចឃាត់ ខ្លួនខ្ញុំកំពង់ឈរលក់ថ្នាំញៀនទៅឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះចំនួន១កញ្ចប់តម្លៃ៤០,០០០រៀល ភ្លាមនេះសមត្ថកិច្ចចុះ ទៅដល់ធ្វើការឃាត់ខ្លួន និងចាប់យកវត្ថុតាងតែម្តង ។ កន្លងមកខ្ញុំបានធ្វើសកម្មភាពលក់ថ្នាំញៀនរយៈពេល២ខែមក ហើយថ្នាំញៀននេះខ្ញុំបានទិញពីក្មេងម្នាក់ដែលរស់នៅម្តុំនេះដោយទិញម្តងតម្លៃ៥០,០០០រៀល ទៅ៦០,០០០ រៀលជា ទូទៅខ្ញុំលក់បានចំនួន៥កញ្ចប់ក្នុងមួយថ្ងៃ ។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ទ័វុត្ថា ឆ្លើយនៅពេលសវនាការថា៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ វេលា ម៉ោង៧,០០នាទីខ្ញុំបានឈរចាំបុរសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ឆ្នាំ ដើម្បីយកគ្រឿងញៀនមកលក់ឱ្យខ្ញុំ រហូតដល់ម៉ោង១០,០០នាទី មានបុរសម្នាក់បានជិះម៉ូតូម៉ាកSUZKI ពណ៌ខ្មៅបានយកគ្រឿងញៀនចំនួន១កញ្ចប់ធំតម្លៃ ៨០,០០០រៀលមកលក់ឱ្យខ្ញុំដោយ១កញ្ចប់យកមកបំបែកបានចំនួន៦០ ទៅ៦៥កញ្ចប់តូច ដោយលក់បាន១កញ្ចប់តូច តម្លៃ១៥,០០០រៀលទៅ ២០,០០០រៀល តែមិនទាន់បានបំបែកលក់ផងស្រាប់តែសមត្ថកិច្ចមកដល់ហើយក៏ធ្វើការឃាត់ ខ្លួនរួចហើយបានធ្វើការឆែកឆេរលើខ្លួនក៏រកឃើញគ្រឿងញៀនដែលលាក់ទុកក្នុងហោប៉ៅខាងឆ្វេង ចំនួន១កញ្ចប់ធំរួចក៏ ធ្វើការឃាត់ខ្លួនរួមជាមួយវត្ថុតាងរួចក៏នាំមកអធិការដ្ឋាននគរបាលខណ្ឌដូនពេញដើម្បីធ្វើការសាកសួរ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានសួរដេញដោលខាងលើឃើញថាជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចន្ទ័វុត្ថា បានឆ្លើយសារភាពថាខ្លួនពិតជាបានលក់ដូរគ្រឿងញៀនពិតប្រាកដមែន ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុកនៅដដែល ដោយចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុ ញៀន ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុម៣៨ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជន ល្មើសទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចន្ទ័វុត្ថា ធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចន្ទ័វុត្ថា បានឆ្លើយថាខ្លួនបានសារ ភាពខ្លួនពិតជាបានធ្វើការជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតមែន ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជន ជាប់ចោទស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនដោយអនុគ្រោះផង ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted]សីហា ស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted]ចន្ទ័វុត្ថា ស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-របាយការសំយោគលេខ០១៧/១៩ រ.ប.ក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ របស់អធិការនគរបាល ខណ្ឌដូនពេញ នៃស្នងការរដ្ឋាននគរបាលរាជធានីភ្នំពេញបានសន្និដ្ឋានថា៖ជនត្រូវចោទឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចន្ទ័វុត្ថា ពិតជាបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវគ្រឿងញៀន កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ ពិតប្រាកដមែន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា ឆ្លើយថា៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង១១,៣០នាទីនៅចំណុចផ្លូវរថភ្លើង ក្រុម៣៩ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ មុនពេលដែលសមត្ថកិច្ចឃាត់ខ្លួនពេលដែលខ្លួនកំពង់ឈរលក់ថ្នាំញៀនទៅឱ្យបុរសម្នាក់មិនស្គាលឈ្មោះចំនួន១កញ្ចប់តម្លៃ ៤០,០០០រៀល ភ្លាមនេះសមត្ថកិច្ចចុះទៅដល់ធ្វើការឃាត់ខ្លួន និងចាប់យកវត្ថុតាងតែម្តង ។ កន្លងមកខ្លួនបានធ្វើសកម្មភាពលក់ថ្នាំញៀនរយៈពេល២ខែមកហើយថ្នាំញៀននេះខ្លួន បានទិញពិក្មេងម្នាក់ដែលរស់នៅម្តុំនេះដោយទិញម្តងតម្លៃ៥០,០០០រៀលទៅ ៦០,០០០ រៀលជាទូទៅខ្លួនលក់បានចំនួន៥កញ្ចប់ក្នុងមួយថ្ងៃ ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ចន្ទ័វុត្ថា ឆ្លើយថា៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង៧,០០នាទីខ្លួនបានឈរចាំបុរសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ឆ្នាំ ដើម្បីយកគ្រឿងញៀនមកលក់ឱ្យខ្លួនរហូតដល់ម៉ោង១០,០០នាទីមានបុរសម្នាក់បានជិះម៉ូតូម៉ាក SUZKI ពណ៌ខ្មៅបានយកគ្រឿងញៀនចំនួន១កញ្ចប់ធំតម្លៃ ៨០,០០០រៀលមកលក់ឱ្យខ្លួនដោយ១កញ្ចប់យកមកបំបែកបានចំនួន៦០ ទៅ៦៥កញ្ចប់តូច ដោយលក់បាន១កញ្ចប់តូចតម្លៃ១៥,០០០រៀលទៅ ២០,០០០រៀល តែមិនទាន់បានបំបែកលក់ផងស្រាប់តែសមត្ថកិច្ចមកដល់ហើយក៏ធ្វើការឃាត់ខ្លួនរួចហើយបានធ្វើការឆែកឆេរលើខ្លួនក៏រកឃើញគ្រឿងញៀនដែលលាក់ទុកក្នុងហោប៉ៅខាងឆ្វេង ចំនួន១កញ្ចប់ធំរួចក៏ធ្វើការឃាត់ខ្លួនរួមជាមួយវត្ថុតាងរួចក៏នាំមកអធិការដ្ឋាននគរបាលខណ្ឌដូនពេញដើម្បីធ្វើការសាកសួរ ។

៤-តាមចម្លើយរបស់ជនជាប់ឈ្មោះ [redacted]សីហា និងឈ្មោះ [redacted]ចន្ទ័វុត្ថា បានឆ្លើយថាខ្លួនពិតជាបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន ចម្លើយនេះស៊ីសង្វាក់ទៅនឹងភស្តុតាងនានានៅក្នុងសំណុំរឿង ។

៥-តាមលទ្ធផលកោសល្យវិច្ឆ័យគ្រឿងញៀនលេខ៣៥៥៩/១៩ ឆ.ត.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ បានបង្ហាញថាគ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted]សីហា និងឈ្មោះ [redacted]ចន្ទ័វុត្ថា បានសន្និដ្ឋានថា៖

ក-សំណាកជាគ្រឿងញៀនប្រភេទម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកំរិតភាពសុទ្ធ៧៥.៨២%(ចិតសិបប្រាំកណ្តក់សញ្ញាប៉ែតសិបពីរ) នៃទម្ងន់សរុប ។

ដូច្នេះក្រាមពណ៌សថ្លាទម្ងន់៤៣,៥១ក្រាមនិងដើម្បីផ្តន្ទាទោសកំណត់ពីទណ្ឌកម្មនៃទោសឱ្យបានត្រឹមត្រូវតាមច្បាប់គប្បីគណនារកសារធាតុញៀន $\frac{\text{៤៣,៥១ក្រាម} \times \text{៧៥,៨២\%}}{\text{១០០}}$ = ៣២,៩៨ក្រាម ដូច្នេះបរិមាណធាតុសុទ្ធសរុបគឺ ៣២,៩៨ក្រាម។

ខ-សំណាកជាគ្រឿងញៀនប្រភេទម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកំរិតភាពសុទ្ធ៧៧.២៥%(ចិតសិបប្រាំពីរកណ្តក់សញ្ញាម្ភៃប្រាំ) នៃទម្ងន់សរុប ។

ដូច្នេះក្រាមពណ៌សថ្លាទម្ងន់៩,៧២ក្រាម និងដើម្បីផ្តន្ទាទោសកំណត់ពីទណ្ឌកម្មនៃទោសឱ្យបានត្រឹមត្រូវតាមច្បាប់គប្បីគណនារកសារធាតុញៀន $\frac{៩,៧២ក្រាម \times ៧៧,២៥\%}{១០០}$ = ៧,៥០ក្រាម ដូច្នេះបរិមាណធាតុសុទ្ធសរុបគឺ៧,៥០ក្រាម។

៦-ជនត្រូវចោទឈ្មោះ [redacted]សីហា និងឈ្មោះ [redacted] ចន្ទ័វុត្ថា មានសតិស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

៧-នៅពេលប្រព្រឹត្តបទល្មើសជនចាប់ចោទមានស្មារតីល្អ អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ដែលផ្ទុយទៅនឹងច្បាប់បានកំណត់ ។

៨-តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុកនៅដដែល ។

៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ-ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ៣១ឆ្នាំ និងឈ្មោះ [redacted] ចន្ទ័វត្ថាហៅ ស្អក ភេទប្រុស អាយុ៣៣ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុម៣៨ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ តាមបញ្ញាតិមាត្រា៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

១០-វត្ថុចាប់យកមានថ្នាំញៀនទម្ងន់សរុប៤៣,៥១ក្រាម ដែលមានធាតុសុទ្ធសរុប៣២,៩៨ក្រាម , កូនថង់ប្លាស្ទិចចំនួន៤ ដែលជារបស់ជនជាប់ឈ្មោះ [redacted] សីហា ,ថ្នាំញៀនទម្ងន់សរុប៩,៧២ក្រាម ដែលមានធាតុសុទ្ធសរុប៧,៥០ក្រាម និងកូនថង់ប្លាស្ទិចចំនួន១ ដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ទ័វុត្ថា គប្បីសម្រេចរឹបអូស ។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោសលើ៖**

ក-ជនជាប់ចោទឈ្មោះ[redacted]សីហា ភេទប្រុស អាយុ៣១ឆ្នាំ ។

ខ-ជនជាប់ចោទឈ្មោះ[redacted] ចន្ទ័វត្ថាហៅ ស្អក ភេទប្រុស អាយុ៣៣ឆ្នាំ ។

-ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ក្រុម៣៨ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ តាមបញ្ញាតិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យកមានថ្នាំញៀនទម្ងន់សរុប៤៣,៥១ក្រាម ដែលមានធាតុសុទ្ធសរុប៣២,៩៨ក្រាម , កូនថង់ប្លាស្ទិចចំនួន៤ ដែលជារបស់ជនជាប់ឈ្មោះ [redacted] សីហា ,ថ្នាំញៀនទម្ងន់សរុប៩,៧២ក្រាម ដែលមានធាតុសុទ្ធសរុប៧,៥០ក្រាម និងកូនថង់ប្លាស្ទិចចំនួន១ ដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ទ័វុត្ថា រឹបអូស ។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនចាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា |

[redacted]

........................................................................................................

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃច័ន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]